# ក្រុមប្រឹក្សារដ្ឋមន្ត្រី

## អនុក្រឹត្យ/០២ អន.ក្រ/២៦ មករា ១៩៩០

## ស្តីពី

## អនាម័យ ចំណីអាហារ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីអំពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញសេចក្តីសំរេចកំណត់លេខ ៨៧-៨០ កច ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៨០ របស់ក្រុមប្រឹក្សាប្រជាជន បដិវត្តកម្ពុជា ស្តីពីតួនាទីភារកិច្ច និងអង្គការចាត់តាំងក្រសួងសុខាភិបាល
- បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ក្រ.ច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សំរេច

## ជំពូកទី១: បទប្បញ្ញត្តិទូទៅ

**មាត្រា១:** អនាម័យចំណីអាហារ គឺជាវិធីសាស្ត្រិះរកគ្រប់វិធានការ ធ្វើអោយចំណីអាហារបានស្អាត បរិសុទ្ធ រក្សាគុណភាពអនាម័យ ដើម្បីធានានូវអនាម័យក្នុងការបរិភោគ។

**មាត្រា២:** ដើម្បីធានាសុខភាពដល់អ្នកបរិភោគចំណីអាហារ ត្រូវតែមានការត្រួតពិនិត្យ។ ចំណីអាហារដែលជាកម្ម- វត្ថុនៃការត្រួតពិនិត្យមាន :

ក- ចំណីអាហារឆ្អិនស្រេច ឬមិនបាច់ចំអិន អាចបរិភោគបានដូចជា: នំ បន្លែ ដំណាប់ ទឹកស៊ីអ៊ីវ សៀងទឹកផឹក ទឹកក្រូច ស្រា សូដា។

ខ- ចំណីអាហារនៅឆៅយកទៅផ្សំ ឬចំអិន ទើបអាចបរិភោគបានមាន: សាច់ជ្រូក-គោ-មាន់-ទា-ត្រី និង សាច់សត្វផ្សេងៗទៀត។

គ- ចំណីអាហារដាក់កំប៉ុង កែវ ដប ស្បោងប្លាស្ទិច ក្រឡ ឬប្រអប់ជាដើម ។

## ជំពូកទី២: ភារកិច្ច និងសិទ្ធិម្ចាស់ចំណីអាហារ

**មាត្រា៣:** មូលដ្ឋានផលិត កន្លែងស្តុក កន្លែងចែកចាយចំណីអាហារ ភោជនីយដ្ឋាន ត្រូវមានទីតាំងសមស្របតាមលក្ខណៈអនាម័យ ។

**មាត្រា៤:** មូលដ្ឋានផលិត កន្លែងស្តុក កន្លែងចែកចាយចំណីអាហារ ភោជនីយដ្ឋានត្រូវបង្កលក្ខណៈងាយស្រួលដល់ក្រុមភ្នាក់ងារអនាម័យក្នុងការត្រួតពិនិត្យ ។

**មាត្រា៥:** អ្នកផលិតចែកចាយ វេចខ្ចប់ចំណីអាហារ អ្នកបំរើក្នុងភោជនីយដ្ឋាន ត្រូវពិនិត្យសុខភាពយ៉ាងតិចប្រាំមួយ ខែម្តង ។

**មាត្រា៦:** មូលដ្ឋានផលិត ម្ចាស់ចំណីអាហារ មានសិទ្ធិប្តឹងតវ៉ាពីក្រុមភ្នាក់ងារអនាម័យក្នុងករណីដែលមានការរំលោភច្បាប់ ឬមិនសុខចិត្តពីលទ្ធផលវិភាគ ឬកោសល្យវិច័យ ។

## ជំពូកទី៣: អំពីសិទ្ធិ និងសមត្ថកិច្ចត្រួតពិនិត្យចំណីអាហារ

**មាត្រា៧:** នៅមជ្ឈិម ការត្រួតពិនិត្យចំណីអាហារ ជាសមត្ថកិច្ចរបស់ក្រុមភ្នាក់ងារអនាម័យចំណីអាហារនៃក្រសួងសុខាភិបាល ។

នៅខេត្ត-ក្រុង ការត្រួតពិនិត្យចំណីអាហារ ជាសមត្ថកិច្ចរបស់ក្រុមភ្នាក់ងារអនាម័យចំណីអាហារដែលតែងតាំងឡើងដោយគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង តាមសំណើរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុង ។

**មាត្រា៨:** ក្រុមភ្នាក់ងារអនាម័យចំណីអាហារ មានសិទ្ធិដូចតទៅ :

ក- ត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ អនុក្រឹត្យសារាចរ សេចក្តីសំរេច បទប្បញ្ញត្តិផ្សេងៗ ដែលពាក់ព័ន្ធនឹងអនាម័យចំណីអាហារ ។

ខ- ហាមឃាត់ការផលិត ការលក់ ការបែងចែកចំណីអាហារដែលមានគុណភាពមិនសមស្របតាមក្បួនអនាម័យ ។

គ- ចេញ-ចូលក្នុងមូលដ្ឋានផលិតចែកចាយចំណីអាហារ ភោជនីយដ្ឋាន ដើម្បីពិនិត្យស្ថានភាពអនាម័យ ។

ឃ- ស្រង់យកគំរូចំណីអាហារសំរាប់ធ្វើការវិភាគក្នុងករណីមានការសង្ស័យថា ខ្វះគុណភាពអនាម័យ

ង- ចេញលិខិតបញ្ជាក់អនាម័យចំណីអាហារអោយម្ចាស់ទំនិញ ឬតំណាង ។

ច- ព្រមាន ឬពិន័យជាប្រាក់ ។

ឆ- ធ្វើកំណត់ហេតុអំពីការត្រួតពិនិត្យ ក្នុងករណីមានបទល្មើស ។

ជ- ឃាត់ទុក ឬបង្វែរទិសនូវចំណីអាហារដែលខ្វះគុណភាពអនាម័យ ។ ក្នុងករណីមានការតវ៉ាអំពីការឃាត់ទុក ការបង្វែរទិស ឬតវ៉ាអំពីប្រាក់ពិន័យ នោះត្រូវក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលខេត្ត-ក្រុង ជាអ្នកពិនិត្យ និងសំរេច ។ ប្រសិនបើមិនព្រមបង់ប្រាក់ពិន័យ នោះត្រូវបញ្ជូនសំណុំរឿង ព្រមទាំងវត្ថុតាង ទៅតុលាការដើម្បីសំរេច ។

**មាត្រា៩:** ក្រសួងសុខាភិបាលមានភារកិច្ចការពារសុខភាពប្រជាជន កាត់ផ្តាច់ការចំលងរោគ និងគ្រោះថ្នាក់បណ្តាលមកពីចំណីអាហារ ព្រមទាំងសហការជាមួយក្រសួងពាក់ព័ន្ធ ធ្វើសេចក្តីណែនាំកំណត់បែបបទលក្ខណៈបច្ចេកទេសនៃការពិនិត្យចំណីអាហារ ដើម្បីធានានូវគុណភាពអនាម័យនៃចំណីអាហារ ។

**មាត្រា១០:** ក្នុងពេលបំពេញភារកិច្ច ភ្នាក់ងារអនាម័យចំណីអាហារ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់ សញ្ញាសំគាល់ មានលិខិតសំគាល់ខ្លួន និងលិខិតបញ្ជាក់បេសកកម្មជាប់នឹងខ្លួន ។

**មាត្រា១១:** រដ្ឋអំណាចមូលដ្ឋាន ត្រូវជួយសហការជាមួយក្រុមភ្នាក់ងារអនាម័យចំណីអាហារ បើមានការស្នើសុំ ។

## ជំពូកទី៤: ទោសប្បញ្ញត្តិ

**មាត្រា១២:** ក្នុងករណីប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនេះ ត្រូវព្រមាន បង្វែរទិស ឬពិន័យជាប្រាក់

- ប្រាក់ពិន័យត្រូវបានជាប្រយោជន៍នៃថវិការដ្ឋ ។

**មាត្រា១៣:** ជនណាប្រព្រឹត្តល្មើសនឹងមាត្រា៣.៤.៥ និងមាត្រា៨ ចំណុច"ខ" នៃអនុក្រឹត្យនេះ ត្រូវព្រមាន ឬពិន័យជាប្រាក់ពី២០រៀល ទៅ២០០រៀល ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេមួយ ជាពីរ ។

**មាត្រា១៤:** ភ្នាក់ងារអនាម័យចំណីអាហារ អ្នកវិភាគ ឬអ្នកធ្វើកោសល្យវិច័យ ខ្វះស្មារតីទទួលខុសត្រូវ ក្នុងភារកិច្ច បណ្តាលអោយខូចប្រយោជន៏ដល់ម្ចាស់ចំណីអាហារ ត្រូវផ្តន្ទាទោសតាមច្បាប់រដ្ឋបាល ដូចជា ព្រមាន ស្តីបន្ទោស បញ្ចុះថ្នាក់ ឬឋានៈអោយលាឈប់ពីការងារដោយបង្ខំ ឬបណ្តេញចេញដោយមិនគិតដល់សំណងនៃការខូចខាតដែលបណ្តាលមកពីអំពើប្រព្រឹត្តរបស់ខ្លួន ។

- ជនណារំលោភលើមុខងារអំណាចរបស់ខ្លួន បណ្តាលអោយខូចទ្រព្យសម្បត្តិរបស់រដ្ឋ ទ្រព្យសម្បត្តិចំរុះរដ្ឋ និងឯកជន សមូហភាព ឯកជន ឬប្រព្រឹត្តបទសំណូក ក្នុងការងារត្រួតពិនិត្យអនាម័យចំណីអាហារ ត្រូវផ្តន្ទាទោសតាម ច្បាប់ជាធរមាន ។

## ជំពូកទី៥: អវសានប្បញ្ញត្តិ

**មាត្រា១៥:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦:** ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងសុខាភិបាល ស្ថាប័ន ក្រសួងពាក់ព័ន្ធ និងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា១៧:** អនុក្រឹត្យនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ។

ភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩០

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

**ជា សុផ្ល**